# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1098

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងជំរុញផលិតកម្មស្បៀង ដំណាក់កាលទី២

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/24 |

៣. ចំណាយគម្រោងសរុប $42,437,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | General Directorate of Agriculture (GDA) |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានកសិកម្ម |

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងជំរុញផលិតកម្មស្បៀងដំណាក់កាលទី២ មានគោលបំណងបន្តកិច្ចអន្តរាគមន៍ ដើម្បីបង្កើនផលិតកម្មបន្លែសុវត្ថិភាព ដើម្បីជំនួសការនាំចូល និងពូជស្រូវក្រអូប។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Research and Extension Services

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

តាកែវ, ត្បូងឃ្មុំ , ព្រៃវែង, សៀមរាប, បាត់ដំបង, ស្ទឹងត្រែង, កំពង់ស្ពឺ, មណ្ឌលគិរី, កំពង់ឆ្នាំង, កំពង់ចាម, កំពង់ធំ, បន្ទាយមានជ័យ, ពោធិ៍សាត់, កណ្ដាល, កំពត,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

១) ជំរុញផលិតកម្មបន្លែសុវត្ថិភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក កាត់បន្ថយការនាំចូលបន្លែពីបរទេស និងឈានទៅរកការនាំចេញបន្លែសុវត្ថិភាពរបស់កម្ពុជាទៅកាន់ទីផ្សារបរទេស។
២) បន្តពង្រីកការប្រើប្រាស់គ្រាប់ពូជស្រូវក្រអូបដែលមានគុណភាពល្អ ដើម្បីចូលរួមការបង្កើនផលិតកម្មស្រូវ គាំទ្រដល់សុវត្ថិភាពនៃការនាំចេញអង្ករបស់កម្ពុជា និងជំរុញការធ្វើពិពិធកម្មដំណាំកសិកម្មប្រកបដោយប្រសិទ្ធភាព។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងជំរុញផលិតកម្មស្បៀង ដំណាក់កាលទី២ នឹងបន្តសហការជាមួយកសិករផលិតបន្លែអាជីព ឈ្មួញ អ្នកបរិភោគ និងសហគមន៍កសិកម្ម ក្នុងខេត្តគោលដៅចំនួន១៥។ គម្រោងនឹងធ្វើការគាំទ្រដល់ផលិតកម្មបន្លែសុវត្ថិភាព ផលិតកម្មពូជស្រូវក្រអូប និងពិពិធកម្មដំណាំ ព្រមទាំងផ្ដល់ការសម្របសម្រួលផ្នែកទីផ្សារ។
គម្រោងនេះ មានសមាសភាគចំនួន៤ គឺ៖
១) សមាសភាគទី១៖ ជំរុញផលិតកម្មដំណាំបន្លែសុវត្ថិភាព
២) សមាសភាគទី២៖ ការពង្រីកផលិតកម្មស្រូវក្រអូប
៣) សមាសភាគទី៣៖ ជំរុញពិពិធកម្មមុខដំណាំកសិកម្ម
៤) សមាសភាគទី៤៖ គ្រប់គ្រងគម្រោង និងពង្រឹងភាពជាដៃគូ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ទោះបីជាមានការវិនិយោគគួរឱ្យកត់សម្គាល់កន្លងមក ដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងវិស័យឯកជន នៅក្នុងផលិតកម្មបន្លែ និងស្រូវក៏ដោយ ក៏ផ្នែកទាំងពីរនេះនៅមានកង្វះខាតជាច្រើនទៀត មិនទាន់បំពេញតម្រូវការបន្លែសុវត្ថិភាព និងពូជស្រូវក្រអូបក្នុងស្រុកនៅឡើយ។ គម្រោងជំរុញផលិតកម្មស្បៀងដំណាក់កាលទី១ ដែលអគ្គនាយកដ្ឋានកសិកម្មបានអនុវត្តកន្លងមក ដោយប្រើប្រាស់ថវិកាជាតិ និងធនធានមនុស្សក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់ពីពាក់កណ្ដាលឆ្នាំ២០១៦កន្លងមក នៅមិនទាន់បានបំពេញគ្រប់គ្រាន់ តាមតម្រូវការដ៏ធំធេងរបស់ផលិតករ និងប្រជាពលរដ្ឋជាអ្នកប្រើប្រាស់នៅឡើយ។ ចំណុចវិជ្ជមានគឺ គម្រោងនេះបានបង្ហាញនូវលទ្ធភាពជាក់ស្ដែងរបស់កសិករ ក្នុងការបង្កើនផលិតកម្មបន្លែសុវត្ថិភាព និងពូជស្រូវក្រអូប ក្រោយពីទទួលបានពីគម្រោងនូវជំនួយបច្ចេកទេស និងការឧបត្ថម្ភផ្នែកសម្ភារនិងថវិកា។ ដើម្បីធានាបាននូវសមិទ្ធិផលច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព សម្រាប់ពង្រីកផលចំណេញហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននៃខេត្តគោលដៅ (១១ ខេត្ត) និងខេត្តបន្តបន្ទាប់ទៀតទៅតាមសក្ដានុពលដាំដុះដំណាំកសិកម្មរបស់ខេត្តនីមួយៗនោះ អគ្គនាយកដ្ឋានកសិកម្ម ត្រូវការបន្តគម្រោងជំរុញផលិតកម្មស្បៀង ដំណាក់កាលទី២ ដែលមានរយៈពេល៥ឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៤។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

កសិករផលិតបន្លែ សហគមន៍កសិកម្ម ឈ្មួញ និងអ្នកបរិភោគទូទៅក្នុងប្រទេសកម្ពុជា។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទាន់ចាប់ផ្ដើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងពុំមានផលប៉ះពាល់ដល់បរិស្ថាននោះទេ។ លើសពីនេះ គម្រោងនឹងជួយកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន តាមរយៈការកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **៦. ធនធានទឹកដែលធន់នឹងទឹកជំនន់ឬគ្រោះរាំងស្ងួត** | 30 | **ទាក់ទងតិចតួច** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនឹងបញ្រ្ជាបការងារយេនឌ័រក្នុងវិស័យកសិកម្ម។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ជាគម្រោងប្រើប្រាស់យន្តការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់កណ្តាល និងរដ្ឋបាលថ្នាក់ខេត្ត នៃរចនាសម្ព័ន្ធមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងករណីខ្វះខាតមន្ត្រី នឹងមានការធ្វើលទ្ធកម្មជួលអង្គ ភាពជំនាញ និងអ្នកជំនាញនៅក្រៅរដ្ឋាភិបាល។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**សំណើគម្រោង មិនទាន់បានអនុវត្តដំណាក់កាលទី២នៅឡើយ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនមាន។**

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 10,023.2 | 15,506.9 | 16,906.9 | 42,437.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 10,023.2 | 15,506.9 | 16,706.9 | 42,237.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 200.0 | 200.0 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 10,023.2 | 15,506.9 | 16,906.9 | 42,437.001 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 10,023.2 | 15,506.9 | 16,906.9 | 42,437.001 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: